Khmer

# ការយល់ព្រមបន្ទាប់ពីបានជ្រាបព័ត៌មាន ក្នុងការថែទាំសុខភាព

## តើការយល់ព្រម បន្ទាប់ពីបានជ្រាបព័ត៌មាន ក្នុងការថែទាំសុខភាពជាអ្វី?

សេវាកម្មសុខភាពនឹងជួយលោកអ្នក ពេលណាលោកអ្នកមានជំងឺ ឬបញ្ហាសុខភាព។ ជួនកាលលោកអ្នកត្រូវការធ្វើតេស្ត ឬការព្យាបាលផ្នែកសុខភាព។ បុគ្គលិកសុខាភិបាលត្រូវតែសួរដើម្បីឲ្យបានដឹង ថាតើលោកអ្នកយល់ព្រមទទួលការធ្វើតេស្ត ឬការព្យាបាលឬអត់។ ការយល់ព្រមបន្ទាប់ពីបានជ្រាបព័ត៌មាន គឺជាពេលដែលលោកអ្នកយល់ច្បាស់ អំពីបញ្ហាជំងឺ និងសុខភាពរបស់លោកអ្នក ហើយយល់ស្របទៅនឹងអ្វីដែលដែលបុគ្គលិកសុខាភិបាលប្រុងនឹងធ្វើ។

លោកអ្នកគួរដឹងអំពីជម្រើសទាំងអស់នៃការថែទាំសុខភាពរបស់លោកអ្នក មុននឹងលោកអ្នកព្រមព្រៀង។ លោកអ្នកអាចជ្រើសរើសទទួលការព្យាបាលឬអត់។

## តើខ្ញុំត្រូវការព័ត៌មានអ្វីខ្លះ?

បុគ្គលិកសុខាភិបាលរបស់លោកអ្នកនឹងផ្តល់ជូនលោកអ្នកនូវព័ត៌មាន ដើម្បីជួយលោកអ្នកធ្វើសេចក្តីសម្រេចអំពីការធ្វើតេស្ត ឬការព្យាបាលរបស់លោកអ្នក។

លោកអ្នកក៏អាចសួរបុគ្គលិកសុខាភិបាលរបស់លោកអ្នកផងដែរនូវសំណួរទាំងឡាយ ដូចជា៖

- តើខ្ញុំមានជំងឺ ឬបញ្ហាសុខភាពអ្វី?
- តើមានការធ្វើតេស្ត ឬការព្យាបាលអ្វី?
- តើការធ្វើតេស្ត ឬការព្យាបាលជួយខ្ញុំបែបណាដែរ?
- តើការធ្វើតេស្ត ឬការព្យាបាល អាចបណ្តាលឲ្យកើតមានបញ្ហាឬទេ?
- តើបញ្ហាទាំងនោះអាចធ្ងន់ធ្ងរយ៉ាងណាដែរ?
- តើមានតេស្ត ឬការព្យាបាលខុសៗគ្នាអ្វីខ្លះ?
- តើមានអ្វីកើតឡើងបន្ទាប់ពីការធ្វើតេស្ត ឬការព្យាបាល?
- តើខ្ញុំនឹងបានជាគ្រាន់បើឬទេ?
- តើវាត្រូវការពេលប៉ុន្មានដែរដើម្បីឲ្យខ្ញុំបានជាគ្រាន់បើ?
- តើអ្វីអាចកើតឡើងប្រសិនបើខ្ញុំពុំទទួលការព្យាបាល?

សូមប្រាប់បុគ្គលិកសុខាភិបាលរបស់លោកអ្នក ប្រសិនបើលោកអ្នកពុំយល់អ្វីមួយ។

## ហេតុអ្វីបានជាខ្ញុំត្រូវតែផ្តល់ការយល់ព្រម?

នៅក្នុងប្រទេសអូស្ត្រាលី វាជាច្បាប់ដែលបុគ្គលិកសុខាភិបាលរបស់លោកអ្នក ត្រូវមានការយល់ព្រមពីលោកអ្នក មុននឹងពួកគេធ្វើតេស្ត ឬព្យាបាល។

## ហេតុអ្វីបានជាខ្ញុំត្រូវចុះហត្ថលេខាលើឯកសារយល់ព្រម?

គេនឹងសុំឲ្យលោកអ្នកចុះហត្ថលេខាលើឯកសារយល់ព្រមជាលាយលក្ខណ៍អក្សរ សម្រាប់ការព្យាបាលដែលប្រឈមគ្រោះថ្នាក់ ដូចជាការវះកាត់។ ពេលដទៃទៀត លោកអ្នកគ្រាន់តែប្រាប់បុគ្គលិកសុខាភិបាលរបស់លោកអ្នកថាលោកអ្នកបានយល់ព្រមប៉ុណ្ណោះ។ មានតែបុគ្គលិកសុខាភិបាលដែលទាក់ទិនក្នុងការធ្វើតេស្ត និងការព្យាបាលរបស់លោកអ្នកប៉ុណ្ណោះ ដែលមើលឯកសារយល់ព្រមរបស់លោកអ្នក។

ឯកសារយល់ព្រមរបស់លោកអ្នកនឹងពុំត្រូវបានចែកចាយទៅឲ្យនរណាផ្សេងទៀត ដែលពុំទាក់ទិនក្នុងការថែទាំសុខភាពរបស់លោកអ្នកឡើយ។

## តើនរណាអាចផ្តល់ការយល់ព្រម?

ប្រសិនបើលោកអ្នកអាចយល់ពីជម្រើសនៃការព្យាបាលរបស់លោកអ្នក ហើយអាចនិយាយប្រាប់បុគ្គលិកសុខាភិបាលរបស់លោកអ្នកអំពីអ្វីដែលលោកអ្នកត្រូវការ នោះលោកអ្នកប្រាកដជាបុគ្គលដែលត្រូវធ្វើសេចក្តីសម្រេច។ លោកអ្នកអាចនាំមិត្តភក្តិ សមាជិកក្រុមគ្រួសារ ឬសមាជិកសហគមន៍មកកាន់ការណាត់ជួបរបស់លោកអ្នក ហើយសុំឱវាទណែនាំអំពីពួកគេបាន។ ជួនកាល បុគ្គលិកសុខាភិបាលរបស់លោកអ្នក សមាជិកក្រុមគ្រួសារ ឬមិត្តភក្តិ អាចធ្វើសេចក្តីសម្រេចសម្រាប់លោកអ្នកក្នុងករណីអាសន្នបាន។

Queensland Government

## តើនរណាផ្ដល់ការយល់ព្រមសម្រាប់កុមារ ?

ជម្មតា ឪពុក ឬម្ដាយ អាណាព្យាបាល ឬអ្នកថែទាំ ផ្ដល់ការយល់ព្រមសម្រាប់កុមារអាយុក្រោម១៨ឆ្នាំ។ ប្រសិនបើកុមារយល់ច្បាស់ពីការព្យាបាលរបស់គេ និងផលប៉ះពាល់សុខភាពរបស់គេ កុមារនោះអាចផ្ដល់ការយល់ព្រមបាន ។ បុគ្គលិកសុខាភិបាលនឹងពិនិត្យមើល ថាតើកុមារអាចផ្ដល់ការយល់ព្រមរបស់ខ្លួនបានដែរឬទេ។

## តើខ្ញុំត្រូវការដឹងប៉ុណ្ណាដែរ ?

បុគ្គលិកសុខាភិបាលនឹងផ្ដល់ព័ត៌មានច្រើនប៉ុណ្ណាក៏បាន តាមដែលលោកអ្នកប្រាថ្នា។ ពួកគេនឹងព្យាយាមឆ្លើយគ្រប់សំណួរទាំងអស់របស់លោកអ្នក។ សូមប្រាប់បុគ្គលិកសុខាភិបាលរបស់លោកអ្នក នូវអ្វីៗដែលអ្នកមិនចង់ដឹងអំពីការធ្វើតេស្ត ឬការព្យាបាលរបស់លោកអ្នក។

## តើខ្ញុំមានពេលប៉ុន្មានដើម្បីធ្វើការសម្រេចចិត្ត ?

សេចក្ដីសម្រេច ត្រូវធ្វើភ្លាមៗក្នុងគ្រាអាសន្ន។ ប្រសិនបើវាមិនបន្ទាន់ទេ លោកអ្នកអាចប្រើពេលវេលាយូរជាងដើម្បីសម្រេចចិត្ត។ ប្រសិនបើលោកអ្នកនៅតែពុំច្បាស់ប្រាកដអំពីការធ្វើតេស្ត ឬការព្យាបាលរបស់លោកអ្នកទេ លោកអ្នកអាចនិយាយទៅកាន់បុគ្គលិកសុខាភិបាលម្នាក់ផ្សេងទៀត ដើម្បីជួយឲ្យលោកអ្នកធ្វើការសម្រេចចិត្ត ។




## តើខ្ញុំត្រូវការអ្នកបកប្រែភាសាឬទេ ?

វាអាចលំបាកយល់អំពីការធ្វើតេស្ត ឬការព្យាបាលផ្នែកសុខភាព។ ដើម្បីធ្វើសេចក្ដីសម្រេចដ៏ល្អបំផុត វាជាការសំខាន់ដែលលោកអ្នក និងបុគ្គលិកសុខាភិបាលរបស់លោកអ្នក យល់គ្នាទៅវិញទៅមក។ ប្រសិនបើភាសាអង់គ្លេសពុំមែនជាភាសាទី១របស់លោកអ្នកទេ គេអាចចាត់ឲ្យមានអ្នកបកប្រែប្រកបដោយវិជ្ជាជីវៈ នៅទីណាត់ជួបរបស់លោកអ្នក។ សេវាបកប្រែផ្ទាល់ ឬតាមទូរស័ព្ទ ឥតមានគិតថ្លៃទេ។ លោកអ្នក ឬបុគ្គលិកសុខាភិបាលរបស់លោកអ្នក អាចស្នើសុំឲ្យមានអ្នកបកប្រែភាសាឲ្យនៅជាមួយលោកអ្នក ពេលណាលោកអ្នកនិយាយអំពីការថែទាំសុខភាពរបស់លោកអ្នក។ ព័ត៌មានដែលលោកអ្នកប្រាប់អ្នកបកប្រែភាសារបស់លោកអ្នក នឹងត្រូវបានរក្សាទុកជាសម្ងាត់។

## ចុះប្រសិនបើខ្ញុំបានផ្ដល់ការយល់ព្រមហើយ រួចមកខ្ញុំផ្លាស់ប្ដូរចិត្តរបស់ខ្ញុំ ?

លោកអ្នកអាចផ្លាស់ប្ដូរចិត្តរបស់លោកអ្នកជានិច្ច ទោះបីជាលោកអ្នកបានចុះហត្ថលេខាលើឯកសារយល់ព្រម ឬបានប្រាប់បុគ្គលិកសុខាភិបាលរបស់លោកអ្នកថាលោកអ្នកយល់ព្រមចំពោះការធ្វើតេស្ត ឬការព្យាបាលហើយក្ដី

# សូមចងចាំ

## ◊ ចូរសួរសំណួរ

វាជាការសំខាន់ដែលលោកអ្នកយល់គ្រប់ទាំងអ្វីៗដែលបុគ្គលិកសុខាភិបាលបានប្រាប់លោកអ្នក។ លោកអ្នកអាចសួរសំណួរច្រើនប៉ុណ្ណាក៏បានតាមដែលលោកអ្នកប្រាថ្នា។ លោកអ្នកអាចនាំនរណាម្នាក់មកជាមួយលោកអ្នកបានដើម្បីជួយគាំទ្រ។

## ◊ ចូរស្នើសុំឲ្យមានអ្នកបកប្រែ

អ្នកបកប្រែភាសាដែលមានវិជ្ជាជីវៈឥតមានគិតថ្លៃទេ។ ពួកគេធ្វើឲ្យលោកអ្នក និងបុគ្គលិកសុខាភិបាលរបស់លោកអ្នក កាន់តែងាយយល់គ្នាទៅវិញទៅមក។

## ◊ វាជាជម្រើសរបស់លោកអ្នក

ទោះបីជាលោកអ្នកបានផ្ដល់ការយល់ព្រមហើយក្ដី លោកអ្នកអាចផ្លាស់ប្ដូរចិត្តរបស់លោកអ្នកបានគ្រប់ពេល។

Partnering with Consumers - This patient information brochure
supports National Safety and Quality Health Service Standard 2 (2.4.1)
Consumers and/or carers provided feedback on this patient information.

This document has been reproduced with the permission of Metro South Hospital and Health Service.

Khmer informed consent
Effective: 10/2016